

NAGAWORLD®
金界

**សម្រាប់ចុះផ្សាយបន្ទាន់ ៖**
**២៧ សីហា ២០១៩**

# ណាហ្គាវើលដ៍ រៀបចំសិក្ខាសាលាបរិស្ថានដើម្បីអនាគតប្រកបដោយនិរន្តរភាព

***រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ៖*** ក្នុងការលើកកម្ពស់ការយល់ដឹងដើម្បីបរិស្ថានកាន់តែស្រស់បំព្រង និងបៃតង "ណាហ្គាវើលដ៍បេះដូងសប្បុរស" ដែលជាក្រុមការងារសង្គមរបស់ក្រុមហ៊ុនណាហ្គាវើលដ៍ បានរៀបចំសិក្ខាសាលាចំនួន ៤ វគ្គដោយសហការជាមួយអង្គការ Plastic Free Cambodia ។ សិក្ខាកាមដែលចូលរួម គឺជាលោកគ្រូ-អ្នកគ្រូមកពីអនុវិទ្យាល័យក្នុងរាជធានីភ្នំពេញ និងបុគ្គលិកណាហ្គាវើលដ៍ ខណៈសិក្ខាសាលាទាំងនេះមានគោលបំណងចែករំលែកអំពីការអនុវត្តល្អបំផុតក្នុងការកាត់បន្ថយកាកសំណល់ប្លាស្ទិក។ បន្ទាប់ពីសិក្ខាសាលា សិក្ខាកាមទាំងអស់នឹងក្លាយជាអ្នកអភិរក្សបរិស្ថានគំរូដែលពួកគេនឹងទៅផ្តល់ចំណេះដឹងបន្តទៅដល់សិស្សានុសិស្ស និងសហគមន៍។

នាយកគ្រប់គ្រងណាហ្គាវើលដ៍ លោក Pern Chen បានមានប្រសាសន៍ថា "ការប្រើប្រាស់ផលិតផលប្លាស្ទិក គឺជារឿងដែលមិនអាចគេចផុតនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ហើយវាផ្តល់ផលប៉ះពាល់គួរឲ្យព្រួយបារម្ភដល់បរិស្ថានរបស់យើង។ ទម្រាំរលាយ ប្លាស្ទិកចំណាយពេលរហូតដល់រាប់រយឆ្នាំ។ ប្លាស្ទិក បញ្ចេញជាតិពុលគីមីទៅក្នុងបរិស្ថានដែលផ្តល់ហានិភ័យយ៉ាងគ្រោះថ្នាក់ដល់មនុស្សជាតិ។ មានកាកសំណល់ប្លាស្ទិកយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានរកឃើញនៅក្នុងសមុទ្ររបស់យើង ដែលវាប៉ះពាល់យ៉ាងខ្លាំងដល់ប្រព័ន្ធអេកូឡូស៊ី ភាវរស់ និងរុក្ខជាតិនៅក្នុងសមុទ្រ"។

លោក Pern Chen បានបន្ថែមថា "យោងទៅតាមរបាយការណ៍របស់ក្រសួងបរិស្ថាន ទីក្រុងភ្នំពេញប្រើប្រាស់ថង់ប្លាស្ទិកជាង ១០ លានថង់រៀងរាល់ថ្ងៃ និងមានកាកសំណល់ជាង ៤ លានតោនជារៀងរាល់ឆ្នាំ។ យើងត្រូវធ្វើចំណាត់ការជាបន្ទាន់ចំពោះស្ថានភាពដ៏អាក្រក់នេះ។ យើងសង្ឃឹមថាការសហការជាមួយអង្គការ Plastic Free Cambodia មិនត្រឹមតែនឹងជួយអប់រំដល់លោកគ្រូ-អ្នកគ្រូ និងបុគ្គលិករបស់យើងឲ្យយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃការបំពុលដោយប្លាស្ទិកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងយល់ដឹងអំពីវិធីកាត់បន្ថយកាកសំណល់ប្លាស្ទិកទៀតផង។ ដោយអនុវត្តទាំងអស់គ្នា យើងនឹងអាចការពារបរិស្ថានរបស់យើង និងធ្វើឲ្យប្រទេសកម្ពុជាកាន់តែស្រស់បំព្រង និងបៃតង។ រួមគ្នាដើម្បីក្លាយជាផ្នែកមួយនៃដំណោះស្រាយជាជាងក្លាយជាផ្នែកមួយនៃការបំពុលបរិស្ថាន"។

ស្ថាបនិកអង្គការ Plastic Free Cambodia អ្នកស្រី Sarah Rhodes បានមានប្រសាសន៍ថា "បេសកកម្មរបស់យើង គឺបញ្ឈប់ការបំពុលដោយប្លាស្ទិក។ យើងចែករំលែកគំនិតផ្តួចផ្តើមដ៏មានសារសំខាន់នេះដើម្បីលើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តឲ្យអ្នករាល់គ្នាចូលរួមកាត់បន្ថយការប្រើប្រាស់



ប្លាស្ទិកនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ យើងក៏មានមោទនភាពផងដែរដែលបានធ្វើការជាមួយក្រុមការងារសង្គមណាហ្គាវើលដ៍បេះដូងសប្បុរសចំពោះគំនិតផ្តួចផ្តើមនេះ៉”។

ណាហ្គាវើលដ៍បេះដូងសប្បុរស មានគំនិតផ្តួចផ្តើមជាច្រើនទៀតពាក់ព័ន្ធនឹងបរិស្ថាន រួមមាន ការដាំកូនឈើជាង ៣.៣០០ ដើមនៅតាមសាលារៀនទូទាំងប្រទេសកម្ពុជា ការដើរប្រមូលសំរាមនៅក្នុងទីក្រុងយ៉ាងទៀងទាត់ ការគាំទ្រដល់ទិវាមួយម៉ោងសម្រាប់ភពផែនដី ការលើកកម្ពស់យុទ្ធសាស្ត្រ ៣R (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) និងយុទ្ធនាការបញ្ឈប់ការប្រើប្រាស់បំពង់បឺតប្លាស្ទិកទូទាំងក្រុមហ៊ុនណាហ្គាវើលដ៍។

###

**អំពីក្រុមការងារសង្គមណាហ្គាវើលដ៍បេះដូងសប្បុរស**

ចាប់តាំងពីបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ណាហ្គាវើលដ៍បាន និងកំពុងធ្វើសកម្មភាពសង្គមប្រកបដោយទឹកចិត្តសប្បុរស និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជាប្រកបដោយភាពវិជ្ជមាន។ ក្នុងខែមីនា ឆ្នាំ ២០១៤ ក្រុមការងារសង្គមណាហ្គាវើលដ៍បេះដូងសប្បុរស ត្រូវបានបង្កើតឡើងដោយបុគ្គលិកណាហ្គាវើលដ៍ដែលមានគោលបំណងផ្តោតទៅលើសសរស្តម្ភ ៤ គឺ ការលើកកម្ពស់វិស័យអប់រំ ការផ្សារភ្ជាប់ជាមួយក្នុងសហគមន៍ ការអភិវឌ្ឍវិស័យកីឡា និងការគាំពារបរិស្ថាននៅក្នុងប្រទេសកម្ពុជា។ មកដល់បច្ចុប្បន្ន មានប្រជាជនកម្ពុជាជាង ២០០.០០០ នាក់បានទទួលផលប្រយោជន៍ពីគំនិតផ្តួចផ្តើមនេះ។

សម្រាប់សំណួរទាក់ទងនឹងការផ្សព្វផ្សាយ ឬរូបភាព សូមទាក់ទងមកកាន់ ៖

| | |
|---|---|
| Ms. Melanie Loong<br>Senior Marketing Communications Manager<br>Tel: (+855) 10 737 684<br>Email: melanieloong@nagaworld.com | កញ្ញា ភោគ សូលីនដា<br>Brand Executive, Marketing Communications<br>Tel: (+855) 15 61 88 86<br>Email: phouksolinda@nagaworld.com |